ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់

# ស្ដីពី

# ការរៀបចំនិងការប្រព្រឹត្តទៅ

# នៃ

# ធនាគារជាតិនៃកម្ពុជា

# ព្រះរាជក្រម

នស/រកម/០១៩៦/២៧

យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិវង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

* * * * * * * * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ០២ នស.៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ៣ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងឯកឧត្តម ថៅ ប៉េងលាត ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង អំពីអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

## ប្រកាសអោយប្រើ

ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃធនាគារជាតិនៃកម្ពុជា ដែលរដ្ឋសភាបានអនុម័តនាសម័យប្រជុំលើកទី៥ នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ជំពូកទី ១
## បទបញ្ញត្តិទូទៅ

**មាត្រា ១.-**

ធនាគារជាតិនៃកម្ពុជាហៅថា "ធនាគារកណ្តាល" គឺជាស្ថាប័នស្វយ័តសាធារណៈមានលក្ខណៈជាពាណិជ្ជកម្មនិងឧស្សាហកម្ម ។

**មាត្រា ២.-**

ធនាគារកណ្តាលជានីតិបុគ្គលមានសមត្ថភាពគតិយុត្តិពេញលេញនិងជាអាទិ៍មានសមត្ថភាពក្នុងការ :

១-ឱ្យប្រាក់គេខ្ចី ខ្ចីប្រាក់ពីគេនិងចុះកិច្ចសន្យាផ្សេងៗទៀត ។

២-ប្តឹងនិងការពារនៅមុខតុលាការ ។

៣-ធ្វើលទ្ធកម្ម កាន់កាប់និងផ្ទេរចេញនូវចលនទ្រព្យនិងអចលនទ្រព្យ ក្នុងគោលដៅនៃការប្រកបអាជីវកម្មរបស់ខ្លួន ។

**មាត្រា ៣.-**

ធនាគារកណ្តាលមានបេសកកម្មចំបងគឺកំណត់និងដឹកនាំនយោបាយរូបិយវត្ថុក្នុងក្របខ័ណ្ឌនយោបាយ សេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅរក្សាថ្លៃឱ្យមានស្ថេរភាពសំដៅបង្កលក្ខណៈងាយស្រួលដើម្បីធ្វើឱ្យសេដ្ឋកិច្ចរីកចំរើន ។

**មាត្រា ៤.-**

ធនាគារកណ្តាលមានសិទ្ធិចេញប្រកាស បទបញ្ជា សារាចរនិងសេចក្តីណែនាំផ្សេងៗទៀតដើម្បីបំពេញបេសកកម្មរបស់ខ្លួននិងដើម្បីអនុវត្តខ្លឹមសារនៃច្បាប់នេះ ។

**មាត្រា ៥.-**

ធនាគារកណ្តាលត្រូវចេញផ្សាយជាប្រក្រតីនូវគោលដៅនយោបាយរូបិយវត្ថុ (រូបិយវត្ថុ ឥណទាន ការប្តូរប្រាក់ អត្រាការប្រាក់)និងស្ថិតិទាក់ទងជាអាទិ៍ដល់បរិមាណរូបិយវត្ថុ ថ្លៃ ឥណទាន ជញ្ជីងទូទាត់និងការប្តូរប្រាក់ ។

**មាត្រា ៦.-**

ទីស្នាក់ការដើមធនាគារកណ្តាលត្រូវតាំងនៅរាជធានីភ្នំពេញ ។ ធនាគារកណ្តាលអាចបើក សាខា ទីភ្នាក់ងារក្នុងប្រទេសនិងការិយាល័យតំណាងនៅឯបរទេស ក្រោយពីមានការយល់ព្រមពីក្រុម ប្រឹក្សាភិបាលនៃធនាគារកណ្តាល ។

# ជំពូកទី ២

## មុខងារនិងភារកិច្ចទូទៅ

**មាត្រា ៧.-**

ធនាគារកណ្តាលមានមុខងារនិងភារកិច្ចដូចតទៅ :

១-កំណត់គោលដៅនយោបាយរូបិយវត្ថុដោយពិគ្រោះជាមួយរាជរដ្ឋាភិបាល ក្នុងក្របខ័ណ្ឌនយោបាយ សេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ។

២-ត្រិះរិះរក អនុវត្តនិងត្រួតពិនិត្យនយោបាយរូបិយវត្ថុនិងប្តូរប្រាក់ឱ្យសំរេចទៅតាមគោលដៅដែល បានកំណត់ ។

៣-ធ្វើការវិភាគស្ថានភាពសេដ្ឋកិច្ចនិងរូបិយវត្ថុជាប្រក្រតីរួចចេញផ្សាយលទ្ធផលហើយលើកសំណើ និងវិធានការជូនរាជរដ្ឋាភិបាល ។

៤-ផ្តល់ឬដកហូតអាជ្ញាប័ណ្ណអាជីវកម្មចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនិងគ្រឹះស្ថានឯទៀត ដែលពាក់ព័ន្ធដូចជា ស្នងការគណនី គ្រឹះស្ថានជម្រះបញ្ជីជាដើមព្រមទាំងចេញបទបញ្ជានិងត្រួតពិនិត្យគ្រឹះស្ថានទាំងនោះ ។

៥-ត្រួតពិនិត្យប្រព័ន្ធទូទាត់ក្នុងព្រះរាជាណាចក្រកម្ពុជានិងកែលំអប្រសិទ្ធិភាពនៃការទូទាត់អន្តរ-ធនាគារ ។

៦-ទទួលភារៈផ្តាច់មុខជាអ្នកបោះផ្សាយរូបិយវត្ថុជាតិនៃព្រះរាជាណាចក្រកម្ពុជា ។

៧-ទទួលខុសត្រូវនិងអនុវត្តក្នុងនាមនៃព្រះរាជាណាចក្រកម្ពុជានូវកិច្ចការទាំងឡាយដែលជាលទ្ធផលនៃការចូលរួមរបស់ព្រះរាជាណាចក្រកម្ពុជាជាមួយស្ថាប័នអន្តរជាតិសាធារណៈ ក្នុងកិច្ចការធនាគារឥណទាននូរូបិយវត្ថុ ។

៨-តម្លើងតារាងជញ្ជីងទូទាត់ ។

៩-ចូលរួមក្នុងការគ្រប់គ្រងបំណុលនិងឥណទេយ្យជាមួយប្រទេសក្រៅ ។

១០-ចូលរួមក្នុងការបង្កើតនិងការត្រួតពិនិត្យទីផ្សាររូបិយវត្ថុនិងទីផ្សារហិរញ្ញវត្ថុ ។

១១-ផ្តល់ឬដកហូតអាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានដែលចូលរួមក្នុងអាជីវកម្មទីផ្សារប្តូរប្រាក់ សង្ហារឹមប័ណ្ណត្បូងថ្ម និងលោហធាតុមានតម្លៃ ព្រមទាំងចេញបទបញ្ជានិងត្រួតពិនិត្យគ្រឹះស្ថានទាំងនេះ ។

១២-កំណត់អត្រាការប្រាក់ ។

**មាត្រា ៨.-**

ធនាគារកណ្តាលអាចបើកគណនីឱ្យ :

-ស្ថាប័នរដ្ឋឬអង្គភាពរដ្ឋបាលកណ្តាល ដូចជារតនាគារជាតិជាដើម

-គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលមានការអនុញ្ញាតពីធនាគារកណ្តាលឱ្យធ្វើអាជីវកម្ម

-ធនាគារកណ្តាលបរទេសនិងស្ថាប័នហិរញ្ញវត្ថុសាធារណៈអន្តរជាតិ ។

ធនាគារកណ្តាលមិនអាចបើកគណនីឱ្យសហគ្រាសឧស្សាហកម្មឬពាណិជ្ជកម្មបានទេ ទោះជារបស់រដ្ឋក៏ដោយ ។

# ជំពូកទី ៣
## ស្វ័យភាពនៃធនាគារកណ្ដាល

**មាត្រា ៩.-**

ដើម្បីបំពេញបេសកកម្មរបស់ខ្លួន ធនាគារកណ្ដាលក្នុងឋានៈជាអ្នកទទួលនូវសិទ្ធិអចិន្ត្រៃយ៍ពីរាជរដ្ឋាភិបាល មានស្វ័យភាពក្នុងការគ្រប់គ្រង តែត្រូវធ្វើរបាយការណ៍ស្ដីពីការអនុវត្តភារកិច្ចនិងលទ្ធផលដែលសំរេចបាន ជូនរដ្ឋសភានិងរាជរដ្ឋាភិបាល ។

ទេសាភិបាលនៃធនាគារកណ្ដាលអាចចូលរួមនិងបញ្ចេញមតិក្នុងអង្គប្រជុំគណៈរដ្ឋមន្ត្រី តាមការអញ្ជើញរបស់រាជរដ្ឋាភិបាល ។ រដ្ឋមន្ត្រីឬរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចចូលរួមនិងបញ្ចេញមតិក្នុងអង្គប្រជុំក្រុមប្រឹក្សាភិបាលនៃធនាគារកណ្ដាល តាមការអញ្ជើញរបស់ក្រុមប្រឹក្សាភិបាលនេះ។

តាមសំណើរបស់រដ្ឋសភា ទេសាភិបាលឬសមាជិកក្រុមប្រឹក្សាភិបាលត្រូវបំភ្លឺអំពីនយោបាយនៃធនាគារកណ្ដាលឬអត្ថាធិប្បាយសេចក្ដីព្រាងច្បាប់ជូនរដ្ឋសភា ឬគណៈកម្មការជំនាញនៃរដ្ឋសភា ។

**មាត្រា ១០.-**

នៅដំណាច់ឆមាសនីមួយៗ ធនាគារកណ្ដាលត្រូវដាក់ជូនរដ្ឋសភានិងរាជរដ្ឋាភិបាលនូវរបាយការណ៍ដោយ :

-វាយតម្លៃនូវគោលធំៗនៃស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជានិងរៀបរាប់អំពីនយោបាយរូបិយវត្ថុនិងនយោបាយប្ដូរប្រាក់ដែលធនាគារកណ្ដាលត្រូវអនុវត្តក្នុងឆមាសបន្ទាប់ ឬក្នុងរយៈពេលវែងជាងនេះ ។

-ពិនិត្យឡើងវិញនិងវាយតម្លៃការអនុវត្តនយោបាយរូបិយវត្ថុនិងនយោបាយប្ដូរប្រាក់ដែលមានចែងក្នុងរបាយការណ៍ឆមាសមុន ។

**មាត្រា ១១.-**

ក្រៅពីរបាយការណ៍ខាងលើ ធនាគារកណ្ដាលត្រូវធ្វើរបាយការណ៍តាមការចាំបាច់របស់រដ្ឋសភានិងរាជរដ្ឋាភិបាល ។

# ជំពូកទី ៤
## ការគ្រប់គ្រងធនាគារកណ្តាល

**មាត្រា ១២.-**

១-អង្គការគ្រប់គ្រងរបស់ធនាគារកណ្តាលគឺក្រុមប្រឹក្សាភិបាល ដែលតទៅនេះហៅកាត់ថា ក្រុមប្រឹក្សា ។ ក្រុមប្រឹក្សាត្រូវបានដឹកនាំដោយទេសាភិបាល ។ ក្រុមប្រឹក្សានេះមានសមាជិក ៧រូប គឺ ទេសាភិបាល ទេសាភិបាលរង និងសមាជិក ៥រូបទៀត ដែល ១រូបតំណាងប្រមុខរដ្ឋាភិបាល ១រូប តំណាងឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូបតំណាងឱ្យមជ្ឈដ្ឋានធ្វើសកម្មភាពសេដ្ឋកិច្ច ១រូបតំណាងឱ្យ មជ្ឈដ្ឋានឧត្តមសិក្សា និង ១រូបទៀតតំណាងឱ្យបុគ្គលិកធនាគារកណ្តាល ។

ក្នុងតំណែងរបស់ខ្លួន ទេសាភិបាលនិងទេសាភិបាលរង មិនអាចជាមន្ត្រីរាជការ មិនអាច ជាទីប្រឹក្សាអង្គភាពសាធារណៈ មិនអាចជាសមាជិករាជរដ្ឋាភិបាលនិងមិនអាចជាសមាជិករដ្ឋសភាទេ ។

លក្ខខណ្ឌខាងលើនេះក៏ត្រូវអនុវត្តចំពោះសមាជិកដទៃទៀតដែរលើកលែងតែតំណាងឱ្យ ប្រមុខរាជរដ្ឋាភិបាលនិងតំណាងឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងតំណាងមជ្ឈដ្ឋានឧត្តមសិក្សាដែល ម្នាក់ៗអាចរក្សាលក្ខណៈជាមន្ត្រីរាជការបាន ។

២-ក្រុមប្រឹក្សាមានភារកិច្ចជាអាទិ៍ :

-រៀបចំនយោបាយសំរាប់កិច្ចប្រតិបត្តិការរបស់ធនាគារកណ្តាល

-ចេញប្រកាស បទបញ្ជា សារាចរ និងសេចក្តីណែនាំផ្សេងៗដើម្បីគ្រប់គ្រងកិច្ចការ ធនាគារកណ្តាល

-ចងក្រងបទបញ្ជាផ្ទៃក្នុង

-តាក់តែងលក្ខន្តិកៈបុគ្គលិក

-បង្កើតនាយកដ្ឋាននានារបស់ធនាគារកណ្តាល

-បង្កើតគណៈកម្មការត្រួតពិនិត្យបញ្ជីគណនេយ្យ

-បង្កើតគណៈកម្មការសំរាប់បណ្តុះបណ្តាលវិជ្ជាជីវៈនៃបុគ្គលិក ។

៣-ទេសាភិបាលមានតួនាទីជាអ្នកដឹកនាំទីមួយនៃធនាគារកណ្តាលនិងទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សា លើកិច្ចការអនុវត្តនយោបាយរបស់ខ្លួន ។ ទេសាភិបាលត្រូវទទួលខុសត្រូវលើការដឹកនាំកិច្ចការរបស់ធនាគារកណ្តាល និងមានសិទ្ធិអំណាចធ្វើកិច្ចការទាំងឡាយណាដែលមិនបានកំណត់សំរាប់ក្រុមប្រឹក្សានៅក្នុងច្បាប់នេះឬបទបញ្ញត្តិទាំងឡាយដែលពាក់ព័ន្ធ ។

ទេសាភិបាលត្រូវតែងតាំងមន្ត្រី បុគ្គលិកនៃធនាគារកណ្តាលនិងលើកសំណើជូនក្រុមប្រឹក្សាក្នុងការកម្រិតប្រាក់បៀវត្ស ព្រមទាំងប្រាក់បំណាច់ផ្សេងៗចំពោះក្របខ័ណ្ឌជាន់ខ្ពស់ ។

៤-ទេសាភិបាលរងមានសិទ្ធិអំណាច និងបំពេញភារកិច្ចទាំងឡាយដែលទេសាភិបាលកំណត់ឱ្យ ។ ក្នុងករណីអវត្តមានរបស់ទេសាភិបាល ទេសាភិបាលរងជំនួសទេសាភិបាល ។

**មាត្រា ១៣.-**

ទេសាភិបាលនិងទេសាភិបាលរងត្រូវបានតែងតាំង ផ្លាស់ប្តូរ បញ្ឈប់ពីតំណែងដោយព្រះរាជក្រឹត្យតាមសំណើរបស់រាជរដ្ឋាភិបាល ។

សមាជិកដទៃទៀតនៃក្រុមប្រឹក្សាត្រូវបានតែងតាំង ផ្លាស់ប្តូរ បញ្ឈប់ពីតំណែងដោយអនុក្រឹត្យ ។ សមាជិកទាំងនេះត្រូវបានជ្រើសរើសតាមបញ្ជីរៀបចំដោយទេសាភិបាលដែលមានឈ្មោះ៣នាក់ក្នុងប្រភេទតំណាងនីមួយៗ ។

**មាត្រា ១៤.-**

១-សមាជិកនៃក្រុមប្រឹក្សាត្រូវតែជាអ្នកដែលគេទទួលស្គាល់ថាមានបទពិសោធន៍និងកិត្តិនាមក្នុងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងមានអាយុមិនលើសពី ៦៥ឆ្នាំ ។ សមាជិកទាំងនោះត្រូវបានតែងតាំងសំរាប់រយៈពេល ៥ឆ្នាំ និងអាចត្រូវបានតែងតាំងជាថ្មីបានតែ ១ដងគត់ ។ ចំពោះក្រុមប្រឹក្សាលើកទី១ ដែលបង្កើតតាមច្បាប់នេះលើកលែងតែទេសាភិបាល ទេសាភិបាលរងនិងតំណាងឱ្យបុគ្គលិកធនាគារកណ្តាល អាណត្តិរបស់សមាជិក ២រូប ត្រូវចប់ក្នុងរយៈ ២ឆ្នាំក្រោយពីថ្ងៃតែងតាំងដោយវិធីចាប់ឆ្នោត ។

សមាជិកក្រុមប្រឹក្សានិងគ្រួសារផ្ទាល់មិនអាចចូលហ៊ុនក្នុងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុណាមួយដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ធនាគារកណ្តាលឡើយ ។

២-សមាជិកនៃក្រុមប្រឹក្សាត្រូវបានបញ្ឈប់ពីតំណែងក្នុងករណី :

ក-ជាប់ទោសពីបទល្មើសព្រហ្មទណ្ឌ បទល្មើសរដ្ឋបាលឬពីបទល្មើសផ្នែកសេដ្ឋកិច្ច ឬផ្នែកពាណិជ្ជកម្ម ។

ខ-មានសេចក្តីសំរេចពីក្រុមប្រឹក្សាថាបានប្រព្រឹត្តបំពានទៅលើការហាមឃាត់ដែលចែងក្នុងមាត្រា ១៥និង១៦នៃច្បាប់នេះ ។

គ-អវត្តមានក្នុងការប្រជុំជាប់ៗគ្នា៤ដង លើកលែងតែមានជម្ងឺនិងក្នុងករណីប្រធានស័ក្តិដែលបានការទទួលស្គាល់ពីក្រុមប្រឹក្សា ។

ឃ-លាឈប់ដោយបានសរសេរជាលាយលក្ខណ៍អក្សរ ។

ង-មិនអាចបំពេញភារកិច្ចរបស់ខ្លួនបានដោយបាត់បង់សមត្ថភាពពលកម្មនិងវិបត្តិស្មារតី ។

ច-ធនក្ស័យផ្ទាល់ខ្លួនដែលប្រកាសដោយតុលាការ ។

៣-ការប្រជុំរបស់ក្រុមប្រឹក្សាត្រូវធ្វើយ៉ាងហោចណាស់ ២ខែម្តង ។

៤-សមាជិកនៃក្រុមប្រឹក្សាត្រូវទទួលកម្រៃក្បាច់វត្តមានដែលក្រុមប្រឹក្សាជាអ្នកកំណត់ ។

៥-ទេសាភិបាលនិងទេសាភិបាលរងទទួលប្រាក់តម្លៃការជាមូលដ្ឋានពីធនាគារកណ្តាលស្មើនិងសមាជិកនៃរាជរដ្ឋាភិបាល ។

**មាត្រា ១៥.-**

១-មិនអនុញ្ញាតឱ្យអ្នកដឹកនាំ បុគ្គលិកឬសមាជិកណាម្នាក់នៃក្រុមប្រឹក្សារបស់ធនាគារកណ្តាល:

-ទាញយកតាមរយៈធនាគារកណ្តាលនូវផលប្រយោជន៍ទាក់ទងនឹងផ្នែកពាណិជ្ជកម្ម ហិរញ្ញវត្ថុ កសិកម្ម ឧស្សាហកម្មឬផ្នែកផ្សេងៗទៀត

-ទទួលយក ដើម្បីផលប្រយោជន៍ទាំងនេះនូវការណែនាំដែលពាក់ព័ន្ធដល់ភារកិច្ចដែលខ្លួនត្រូវបំពេញដូចមានចែងក្នុងច្បាប់នេះ

-ទទួលធ្វើការងារណាដែលផ្ទុយពីភារកិច្ចរបស់ខ្លួន

-ទទួលអំណោយឬលាភសក្ការៈសំរាប់ខ្លួនឯងផ្ទាល់ឬសំរាប់បុគ្គលជិតស្និទ្ធិជាមួយខ្លួនដែលជាគ្រួសារផ្ទាល់ក្តី ជាភាគីពាណិជ្ជកម្មឬហិរញ្ញវត្ថុក្តីដោយលំអៀងនូវភាពស្មោះត្រង់ក្នុងការបំពេញភារកិច្ច។

២-សមាជិកទាំងអស់នៃក្រុមប្រឹក្សាត្រូវរាយការណ៍ឱ្យបានសព្វគ្រប់ជូនទៅក្រុមប្រឹក្សាអំពីផលប្រយោជន៍សំខាន់ៗផ្នែកពាណិជ្ជកម្ម ហិរញ្ញវត្ថុ កសិកម្ម ឧស្សាហកម្មឬរបរអាជីវកម្មផ្សេងទៀតដែលខ្លួនឬគ្រួសារផ្ទាល់មានដោយចំពោះឬដោយប្រយោល ហើយពុំមានសិទ្ធិបោះឆ្នោតលើបញ្ហាទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងផលប្រយោជន៍របស់ខ្លួនឡើយ ។ ប៉ុន្តែអាចចូលរួមដើម្បីបំពេញចំនួនកូរ៉ុមក្នុងអង្គប្រជុំ ដែលត្រូវបានកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា ។

**មាត្រា ១៦.-**

អ្នកដឹកនាំ បុគ្គលិកនិងសមាជិកនៃក្រុមប្រឹក្សារបស់ធនាគារកណ្តាលមិនត្រូវផ្តល់ឱ្យអ្នកដទៃនូវព័ត៌មានដែលទាក់ទងនឹងការសម្ងាត់វិជ្ជាជីវៈដែលខ្លួនបានទទួលក្នុងពេលបំពេញភារកិច្ចឡើយ លើកលែងតែក្នុងករណីចាំបាច់ដែលច្បាប់អនុញ្ញាតឬមានការបង្គាប់ពីតុលាការ ។

## ជំពូកទី ៥
## ដើមទុន ការប្រើប្រាស់ប្រាក់ចំណេញនិងទុនបំរុង

**មាត្រា ១៧.-**

១-ធនាគារកណ្តាលត្រូវបានអនុញ្ញាតឱ្យមានដើមទុនដែលកម្រិតដោយអនុក្រឹត្យ ។ ដើមទុននេះអាចកែប្រែបានតាមពេលវេលាចាំបាច់ ។ ដើមទុនទាំងមូលត្រូវបានចុះបញ្ជីនិងកាន់កាប់ផ្តាច់មុខដោយរាជរដ្ឋាភិបាលនិងមិនអាចផ្ទេរឬដាក់ឱ្យជាប់ល័ក្ខខ័ណ្ឌអ្វីឡើយ ។

២-នៅពេលដែលទ្រព្យសកម្មពិតក្នុងតារាងតុល្យការរបស់ធនាគារកណ្តាលថយចុះក្រោមចំនួនទ្រព្យអកម្ម រាជរដ្ឋាភិបាលត្រូវប្រគល់ជូនធនាគារកណ្តាលនូវមូលប័ត្ររដ្ឋដើម្បីបំពេញឱនភាពនោះក្នុងកំឡុង ៦០ថ្ងៃ ក្រោយពីពេលចេញផ្សាយតារាងតុល្យការរបស់ធនាគារកណ្តាល ។ មូលប័ត្ររដ្ឋជាប័ណ្ណអាចធ្វើអន្តរការបានដោយគិតការប្រាក់តាមអត្រាបុនហិរញ្ញប្បទាន ។

**មាត្រា ១៨.-**

លទ្ធផលជាមូលដ្ឋាននៃការិយបរិច្ឆេទនីមួយៗរបស់ធនាគារកណ្តាលត្រូវបានគណនា ក្រោយពីបានដកចំណាយប្រតិបត្តិការប្រចាំការិយបរិច្ឆេទនោះនិងក្រោយពីបានដកទុកសំរាប់ :

១-ទាយជ្ជទានដល់គណនីសិវិធានធនសំរាប់ហានិភ័យនិងការស្រុតចុះតម្លៃនិងដល់គណនីរំលស់ទ្រព្យសកម្ម ។

២-សំវិធានធនដល់មូលនិធិសោធនដែលកំណត់ដោយក្រុមប្រឹក្សា ។

៣-ប្រាក់បំរុងទូទៅស្មើនឹង ២០% ( ម្ភៃភាគរយ ) លើលទ្ធផលក្រោយពីដកក្នុងចំណុច ១និង២នៃមាត្រានេះ ។

៤-ប្រាក់បំរុងសំរាប់សងថ្លៃមូលប័ត្រទាំងឡាយដែលធនាគារកណ្តាលបានទទួល ។

៥-មូលនិធិសំរាប់វិនិយោគសម្ភហភាពរបស់ធនាគារកណ្តាលដែលកំណត់ដោយក្រុមប្រឹក្សា។

**មាត្រា ១៩.-**

ប្រាក់ចំណេញសុទ្ធត្រូវបង់ចូលថវិកាជាតិក្រោយពីបានដកចេញ :

- ៥% ( ប្រាំភាគរយ ) សំរាប់រង្វាន់បុគ្គលិកដោយមិនគិតក្រុមប្រឹក្សា ។
- ០,៥% ( សូន្យក្បៀសប្រាំភាគរយ ) សំរាប់សមាជិកក្រុមប្រឹក្សា ។

**មាត្រា ២០.-**

គម្រោងចំណាយទាំងអស់របស់ធនាគារកណ្តាលត្រូវចងក្រងក្នុងថវិកាប្រចាំឆ្នាំរបស់ខ្លួន ដែលត្រូវអនុម័តដោយក្រុមប្រឹក្សាហើយផ្ញើជូនរាជរដ្ឋាភិបាលនិងរដ្ឋសភាដើម្បីជាពត៌មាន ។

## ជំពូកទី ៦

## សម្ព័ន្ធការផ្គត់ផ្គង់រូបិយវត្ថុជាមួយអង្គភាពសាធារណៈ

**មាត្រា ២១.-**

១-ធនាគារកណ្តាលទទួលប្រាក់បញ្ញើផ្តាច់មុខជារូបិយវត្ថុជាតិពីរតនាគារជាតិ ។ ធនាគារកណ្តាលទទួលប្រាក់ពីរតនាគារជាតិ ហើយចេញជូសនូវទឹកប្រាក់ដែលរតនាគារជាតិត្រូវចំណាយ ។

ធនាគារកណ្តាលត្រូវកំណត់ជាមួយនឹងរតនាគារជាតិនូវកម្រៃដែលត្រូវបង់ជូនធនាគារកណ្តាលលើរាល់ប្រតិបត្តិការដែលត្រូវអនុវត្ត ។

២-ចំណូលជារូបិយប័ណ្ណរបស់រតនាគារជាតិត្រូវលក់ឱ្យធនាគារកណ្តាល ហើយធនាគារកណ្តាលត្រូវបញ្ចូលទឹកប្រាក់ជារៀលក្នុងគណនីតែមួយរបស់រតនាគារជាតិដោយគិតតាមអត្រាប្តូរប្រាក់ប្រចាំថ្ងៃ ។

**មាត្រា ២២.-**

ធនាគារកណ្តាលជាទីប្រឹក្សារបស់រាជរដ្ឋាភិបាលក្នុងវិស័យរូបិយវត្ថុនិងហិរញ្ញវត្ថុ ។

ធនាគារកណ្តាលមានភារកិច្ចក្នុងការផ្តល់ពត៌មាននិងយោបល់ជូនរាជរដ្ឋាភិបាលអំពីបញ្ហាទាំងឡាយដែលមានអានុភាពក្នុងការធ្វើឱ្យសំរេចគោលដៅនយោបាយនៃហិរញ្ញវត្ថុ ។

**មាត្រា ២៣.-**

១-ធនាគារកណ្តាលត្រូវជួយគ្រប់គ្រងក្នុងការខ្ចីប្រាក់របស់រាជរដ្ឋាភិបាលឬអង្គភាពសាធារណៈដោយធ្វើប្រតិបត្តិការលើមូលប័ត្រជាអាទិ៍ ជូនយោបល់លើកាលបរិច្ឆេទនៃការបោះផ្សាយមូលប័ត្រនិងជំរុញទីផ្សាររូបិយវត្ថុនិងទីផ្សារហិរញ្ញវត្ថុឱ្យរីកចំរើន ។

២-ធនាគារកណ្តាលអាចទទួលធ្វើជាអាណត្តិគាហករបស់រាជរដ្ឋាភិបាលឬរបស់អង្គភាពសាធារណៈចំពោះប្រតិបត្តិការដូចខាងក្រោមនេះ :

-ការទិញ លក់មូលប័ត្រដែលបោះផ្សាយដោយរាជរដ្ឋាភិបាលឬអង្គភាពសាធារណៈព្រមទាំងកិច្ចការជាភ្នាក់ងារគណនេយ្យដើម្បីចុះបញ្ជីនិងផ្ទេរនូវមូលប័ត្រនោះ

-ការទូទាត់សងដើមនិងការប្រាក់ព្រមទាំងកម្រៃផ្សេងៗលើមូលប័ត្រទាំងនោះ ។

៣-ធនាគារកណ្តាលត្រូវកំណត់ជាមួយរាជរដ្ឋាភិបាលឬអង្គភាពសាធារណៈ អំពីកម្រៃដែលត្រូវបង់ជូនធនាគារកណ្តាលលើរាល់ប្រតិបត្តិការដែលមានចែងក្នុងចំណុច ២នៃមាត្រានេះ ។

**មាត្រា ២៤.-**

ធនាគារកណ្តាលមិនត្រូវផ្តល់ឥណទានដោយផ្ទាល់ឬដោយប្រយោលដល់រាជរដ្ឋាភិបាលឡើយ ជាពិសេសដោយទិញយកមូលប័ត្រដែលបោះផ្សាយដំបូងឬមូលប័ត្រដែលធានាដោយរាជរដ្ឋាភិបាលឬដោយអង្គភាពសាធារណៈ លើកលែងតែករណីស្របទៅនឹងបទបញ្ញត្តិនានាក្នុងជំពូកនេះ ។

**មាត្រា ២៥.-**

ធនាគារកណ្តាលអាចផ្តល់ឥណទានដែលមានកាលវសានមិនហួសពី ៣ខែជូនទៅរតនាគារជាតិដោយគិតការប្រាក់តាមអត្រាបុនហិរញ្ញប្បទាន :

១-រាល់ប្រតិបត្តិការឥណទានត្រូវមានកិច្ចព្រមព្រៀងរវាងធនាគារកណ្តាលនិងអ្នកខ្ចីដែលត្រូវមានបញ្ជាក់ទឹកប្រាក់ឥណទាន កាលវសាននិងអត្រាការប្រាក់ ។

២-ប្រតិបត្តិការឥណទានត្រូវធ្វើឱ្យមានយថាភាពដោយប្រគល់ជូនធនាគារកណ្តាលនូវមូលប័ត្ររដ្ឋដែលអាចធ្វើអន្តរការបាន ។

៣-ចំនួនទឹកប្រាក់សរុបនៃឥណទាននិងមូលប័ត្រដែលមានស្របតាមមាត្រា ២៤នៃច្បាប់នេះក្នុងការិយបរិច្ឆេទនីមួយៗមិនត្រូវឱ្យលើសពី ១០% ( ដប់ភាគរយ ) នៃចំណូលធម្មតានៃថវិកាជាតិក្នុងការិយបរិច្ឆេទនាឆ្នាំមុនឡើយ ដោយមិនគិតជំនួយនិងចំណូលពីការលក់ទ្រព្យសម្បត្តិ ។

**មាត្រា ២៦.-**

នៅក្នុងក្របខ័ណ្ឌនៃកិច្ចប្រតិបត្តិការផ្សារចំហឬកិច្ចប្រតិបត្តិការអប្បហារឬឥណទានជាមួយនឹងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ធនាគារកណ្តាលអាចលក់ ទិញ ទទួលឬដាក់បំង់ស្យុងនៃមូលប័ត្ររដ្ឋដែលត្រូវបានគេបោះផ្សាយជាសាធារណៈពីមុនមក ហើយដែលត្រូវផុតកំណត់សងក្នុងកំឡុង ៩០ថ្ងៃ ។

**មាត្រា ២៧.-**

ជារៀងរាល់ឆ្នាំរាជរដ្ឋាភិបាលត្រូវពិគ្រោះជាមួយធនាគារកណ្តាលសិន មុននិងសំរេចថវិកាជាតិជាស្ថាពរដើម្បីកំណត់នូវចំនួនទឹកប្រាក់ឥណទានសរុបដែលរាជរដ្ឋាភិបាលនិងអង្គភាពសាធារណៈនានាអាចត្រូវការពីធនាគារកណ្តាលក្នុងកម្រិតដូចមានចែងក្នុងមាត្រា ២៥នៃច្បាប់នេះ ។

**មាត្រា ២៨.-**

ធនាគារកណ្តាលចូលរួមក្នុងការគ្រប់គ្រងបំណុលសាធារណៈក្នុងនិងក្រៅប្រទេសដោយរាប់បញ្ចូលទាំងលិខិតធានារ៉ាប់រងចេញជូនឥណទាយកផង ។

# ជំពូកទី ៧
## របបនិងនយោបាយប្តូរប្រាក់

**មាត្រា ២៩.-**

ធនាគារកណ្តាលត្រូវកំណត់និងអនុវត្តរបបនិងនយោបាយប្តូរប្រាក់នៃព្រះរាជាណាចក្រកម្ពុជា ដោយពិគ្រោះជាមួយរាជរដ្ឋាភិបាលក្នុងក្របខ័ណ្ឌនយោបាយសេដ្ឋកិច្ច ហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៣០.-**

១-ធនាគារកណ្តាលត្រូវរក្សានិងគ្រប់គ្រងទុនបំរុងផ្លូវការក្រៅប្រទេសដែលរួមមាន :

-មាសរូបិយវត្ថុ

-រូបិយប័ណ្ណដែលមានទ្រង់ទ្រាយជាក្រដាសឬជាកាសនិងសមតុល្យធនាគារនៅបរទេស

-ធនធានជាទុនបំរុងដែលអន្តរជាតិទទួលស្គាល់ជាអាទិ៍មាន :

•រូបិយប័ណ្ណដែលទិញពីមូលនិធិរូបិយវត្ថុអន្តរជាតិយកក្នុងផ្នែកបំរុង

•ធនធានជាសិទ្ធិដកពិសេស អេស.ឌី.អរ ( S.D.R ) របស់ព្រះរាជាណាចក្រកម្ពុជា

-រូបិយាណត្តិនិងប័ណ្ណសងតាមបញ្ជាដែលមានកំណត់ជារូបិយប័ណ្ណហើយត្រូវសងនៅក្រៅប្រទេស

-ប័ណ្ណរតនាគារដែលបោះផ្សាយដោយរដ្ឋាភិបាលបរទេស

-មូលប័ត្រដែលបោះផ្សាយឬធានាដោយរដ្ឋាភិបាលបរទេសឬស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា ។

២-ធនាគារកណ្តាលត្រូវរក្សាទុនបំរុងក្រៅប្រទេសឱ្យនៅកម្រិតគ្រប់គ្រាន់ដើម្បីធានាដល់ប្រតិបត្តិការអន្តរជាតិរបស់ព្រះរាជាណាចក្រកម្ពុជា ។

៣-កាលណាទុនបំរុងផ្លូវការក្រៅប្រទេសមានការថយចុះឬមានភាពដែលអាចថយចុះដល់កម្រិតខ្វះខាត ធនាគារកណ្តាលត្រូវដាក់ជូនដល់រាជរដ្ឋាភិបាលនូវរបាយការណ៍ស្តីពីមូលហេតុនៃបញ្ហានិងវិធានការដើម្បីកែសម្រួល ។ របាយការណ៍នេះត្រូវធ្វើជាប្រចាំរហូតដល់ស្ថានភាពថយចុះខាងលើត្រូវបានដោះស្រាយរួចជាស្រេច ។

៤-ធនាគារកណ្ដាលជាអ្នកទទួលបន្ទុកថែរក្សាធនធានផ្លូវការក្រៅប្រទេសរបស់ព្រះរាជា-ណាចក្រកម្ពុជា ហើយមានសិទ្ធិជ្រើសរើសអាណត្តិគាហកដែលជាស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ធនាគារកណ្ដាលឬធនាគារពាណិជ្ជកម្មបរទេសដើម្បីកាន់កាប់ជំនួស ។

**មាត្រា ៣១.-**

១-ធនាគារកណ្ដាលត្រូវកំណត់អត្រាប្ដូរប្រាក់នៃរូបិយវត្ថុជាតិឱ្យមាននិយតភាព ។ ដូច្នេះធនាគារកណ្ដាលមានសិទ្ធិជាអាទិ៍ :

-ធ្វើអាជីវកម្មលើមាសជាកាសឬជាដុំនិងលើលោហៈធាតុឬត្បូងថ្មមានតម្លៃផ្សេងទៀត

-ធ្វើអាជីវកម្មលើរូបិយប័ណ្ណដោយប្រើឧបករណ៍នានាដែលធនាគារិកធ្លាប់ប្រើជាទូទៅ

-ធ្វើអាជីវកម្មលើប័ណ្ណរតនាគារឬលើមូលប័ត្រផ្សេងទៀត ដែលបោះផ្សាយឬធានាដោយរដ្ឋាភិបាលបរទេសឬស្ថាប័នហិរញ្ញវត្ថុសាធារណៈអន្តរជាតិ

-បើកនិងកាន់កាប់គណនីធនាគារពាណិជ្ជឬស្ថាប័នហិរញ្ញវត្ថុសាធារណៈអន្តរជាតិនៅឯបរទេស

-បើកនិងកាន់កាប់គណនី និងធ្វើសកម្មភាពជាភ្នាក់ងារឬជាអ្នកទាក់ទងជំនួសមុខធនាគារកណ្ដាលបរទេស រដ្ឋាភិបាលបរទេស ទីភ្នាក់ងាររដ្ឋាភិបាលបរទេសនិងស្ថាប័នហិរញ្ញវត្ថុសាធារណៈអន្តរជាតិនានា

-កំណត់អត្រាទិញ លក់រូបិយប័ណ្ណនានា

-កម្រិតស្ថានភាពរូបិយប័ណ្ណនៃធនាគារពាណិជ្ជនិងទីកន្លែងប្ដូរប្រាក់ដែលមិនមែនជាធនាគារ

-ចេញបទបញ្ញាដែលពាក់ព័ន្ធលើការប្ដូរប្រាក់និងអាជីវកម្មលើមាស លោហៈធាតុនិងត្បូងថ្មមានតម្លៃ

-ប្រកាសអត្រាប្ដូររវាងប្រាក់រៀលនិងរូបិយប័ណ្ណផ្សេងៗ

-ចូលរួមក្នុងកិច្ចព្រមព្រៀងរូបិយវត្ថុអន្តរជាតិជំនួសមុខឱ្យរដ្ឋ

២-ធនាគារកណ្ដាលមិនអាចផ្ដល់ឱ្យអ្នកដទៃនូវលិខិតធានាអត្រាប្ដូរប្រាក់ទៅអនាគត ហើយមិនអាចអនុញ្ញាតឬមិនត្រូវប្រើពហុអត្រាឡើយ ។

**មាត្រា ៣២.-**

១-ប្រាក់តម្លៃលើសសុទ្ធក្នុងពេលបិទបញ្ជីម្តងៗដែលកើតមានឡើងពីការប្រែប្រួលតម្លៃទ្រព្យសកម្មនិងទ្រព្យអកម្មនៃធនាគារកណ្តាលដែលកត់ត្រាជារូបិយប័ណ្ណឬឯកតាគណនីឯទៀតក្រៅពីរូបិយវត្ថុជាតិ ត្រូវចុះជាឥណទាននៅក្នុងគណនីទុនបំរុងពិសេស ។

២-ប្រាក់តម្លៃខ្វះសុទ្ធក្នុងពេលបិទបញ្ជីម្តងៗដែលកើតមានឡើងពីការប្រែប្រួលដូចខាងលើនេះ ត្រូវកត់ត្រាបញ្ចូលពីសមតុល្យឥណទាយីនៃគណនីទុនបំរុងពិសេស ហើយបើសមតុល្យនោះមានបរិមាណមិនគ្រប់គ្រាន់ដើម្បីទូទាត់ប្រាក់ខ្វះទាំងនោះទេ រតនាគារជាតិត្រូវចេញមូលប័ត្រដែលអាចធ្វើអន្តរការបានដោយគិតការប្រាក់តាមអត្រាបុនហិរញ្ញប្បទានទៅឱ្យធនាគារកណ្តាលដើម្បីបង្គ្រប់ឱនភាព ។

៣-ទាំងប្រាក់តម្លៃលើសសុទ្ធ ទាំងប្រាក់តម្លៃខ្វះសុទ្ធដែលចែងក្នុងមាត្រានេះមិនត្រូវគិតចូលក្នុងតារាងប្រតិលាភប្រចាំឆ្នាំរបស់ធនាគារកណ្តាលឡើយ ។

៤-រាល់សមតុល្យឥណទាយីក្នុងគណនីទុនបំរុងពិសេស នៅចុងការិយបរិច្ឆេទនៃធនាគារកណ្តាល ត្រូវប្រើសំរាប់សងមូលប័ត្រដែលត្រូវបានបោះផ្សាយដូចមានចែងក្នុងចំណុច ២នៃមាត្រានេះ ។

៥-សមតុល្យគណនីទុនបំរុងពិសេសនេះមិនត្រូវមានការតម្រឹមតម្រង់ឡើយ លើកលែងតែអនុលោមតាមមាត្រានេះ ។

## ជំពូកទី ៨

## សម្ព័ន្ធការជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

**មាត្រា ៣៣.-**

ធនាគារកណ្តាលត្រូវទទួលខុសត្រូវផ្តាច់មុខក្នុងការផ្តល់ឬដកហូតអាជ្ញាប័ណ្ណនិងការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនិងគ្រឹះស្ថានឯទៀតដូចមានចែងក្នុងមាត្រា ៧នៃច្បាប់នេះដោយ :

១-ចេញប្រកាស បទបញ្ជានិងការណែនាំផ្សេងៗព្រមទាំងចាត់វិធានការចាំបាច់ដើម្បីធ្វើឱ្យសំរេចមុខងារដែលមានចែងក្នុងជំពូកទី២នៃច្បាប់នេះដោយអនុវត្តបទដ្ឋាននៃការផ្តល់ឬដកហូតអាជ្ញាប័ណ្ណនិងត្រួតពិនិត្យព្រមទាំងមធ្យោបាយសមស្រប ។

២-ចាត់តាំងបុគ្គលិករបស់ខ្លួនឬបុគ្គលដទៃទៀតដែលមានសមត្ថភាពឱ្យត្រួតពិនិត្យជានិច្ចកាលលើលិខិតស្នាមនិងចុះធ្វើអធិការកិច្ចដល់កន្លែង ព្រមទាំងពិនិត្យបញ្ជី ការចុះបញ្ជីនិងឯកសារផ្សេងៗរបស់គ្រឹះស្ថានទាំងនេះ ។

៣-តម្រូវឱ្យអភិបាលឬបុគ្គលិកគ្រឹះស្ថានទាំងនោះផ្តល់ដល់ធនាគារកណ្តាលនូវពត៌មាននានាសំរាប់ធ្វើការត្រួតពិនិត្យនិងកែតំរូវ ។

៤-ប្តឹងទៅតុលាការឬដាក់កម្មវិបាកតាមច្បាប់ជាធរមាន ប្រសិនបើមានការប្រព្រឹត្តល្មើសដោយគ្រឹះស្ថាន ឬដោយអភិបាលបុគ្គលិករបស់គ្រឹះស្ថាននោះ :

-បំពានបទបញ្ញត្តិនៃច្បាប់ជាធរមាន ឬបទបញ្ជារបស់ធនាគារកណ្តាល

-ការខ្វះខាតក្នុងការបំពេញភារកិច្ចផ្សេងៗ

-មិនគោរពវិធានការនយោបាយរូបិយវត្ថុឬវិធានការប្រុងប្រយ័ត្ននានាដែលបានកំណត់ ។

**មាត្រា ៣៤.-**

ធនាគារកណ្តាលមានសិទ្ធិបើកគណនីនិងទទួលប្រាក់បញ្ញើពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលធ្វើអាជីវកម្មក្នុងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងផ្តល់ការប្រាក់និងយកកម្រៃដែលធនាគារកណ្តាលជាអ្នកកំណត់ ។

**មាត្រា ៣៥.-**

១-ធនាគារកណ្តាលចេញបទបញ្ជាដោយផ្សព្វផ្សាយឬជូនដំណឹងជាលាយល័ក្ខណ៍អក្សរដល់ទីស្នាក់ការរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីតម្រូវឱ្យគ្រឹះស្ថានទាំងនោះតំកល់ទុនបំរុងកាតព្វកិច្ច ។ ទុនបំរុងនេះត្រូវរក្សាជាសាច់ប្រាក់ក្នុងបេឡារបស់ខ្លួនឬជាប្រាក់បញ្ញើពិសេសក្នុងគណនីចរន្តនៅធនាគារកណ្តាល ។

២-ធនាគារកណ្តាលតម្រូវមេគុណទុនបំរុងដូចគ្នាចំពោះកិច្ចសន្យាសទិស ។ ចំនួនទឹកប្រាក់ទុនបំរុងតម្កល់ទុករបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវបានកំណត់ដោយយោលទៅតាមប្រាក់បញ្ញើនិងកិច្ចសន្យាសទិសផ្សេងៗទៀតដែលគ្រឹះស្ថានធ្វើជាមួយអតិថិជន ។

រាល់ការកំណត់ឬការបង្កើនមេគុណទុនបំរុងកាតព្វកិច្ចនឹងចូលជាធរមាន១ខែចាប់ពីពេលដែលគ្រឹះស្ថាននោះបានទទួលដំណឹងជាលាយល័ក្ខណ៍អក្សរ ។

ធនាគារកណ្តាលអាចលើកលែងការតម្កល់ទុនបំរុងជូនគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុប្រភេទខ្លះ

៣-ធនាគារកណ្តាលដាក់ពិន័យដោយយកកម្រៃជើងសាក្នុងមួយថ្ងៃដែលស្មើនឹង ១/១០ (មួយភាគដប់) នៃអត្រាបុនហិរញ្ញប្បទានចុងក្រោយរបស់ធនាគារកណ្តាលលើគ្រឹះស្ថានទាំងឡាយណាដែលមិនគោរពទុនបំរុងកាតព្វកិច្ច ។ កម្រៃជើងសាទាំងនេះអាចដកយកពីសមតុល្យនៃគណនីរបស់គ្រឹះស្ថាននោះដែលមានបើកនៅធនាគារកណ្តាល ។

**មាត្រា ៣៦.-**

១-ធនាគារកណ្តាលត្រូវកំណត់បែបបទហើយទិញ លក់ជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឬធ្វើអប្បហារ បុនប្បហារ ក៏ដូចជាធ្វើកិច្ចប្រតិបត្តិការប៉ង់ស្យុងនូវ :

ក-រូបិយាណត្តិឬប័ណ្ណសងតាមបញ្ជាដែលបោះផ្សាយ ឬធ្វើឡើងសំរាប់ផ្នែកពាណិជ្ជកម្ម ឧស្សាហកម្ម ឬកសិកម្មជាយថាភូតដោយមានហត្ថលេខាសាធនីយពីរយ៉ាងតិច ក្នុងនោះយ៉ាងហោចណាស់ត្រូវមានហត្ថលេខាមួយជារបស់ធនាគារពាណិជ្ជដែលមានកាលវសាន ៩០ថ្ងៃ ចាប់ពីថ្ងៃដែលបានទទួល ក៏ប៉ុន្តែរូបិយាណត្តិនិងប័ណ្ណសងតាមបញ្ជាដែលចេញឬធ្វើឡើងសំរាប់ហិរញ្ញប្បទាន ផលិតកម្មឬពាណិជ្ជកម្មធញ្ញជាតិ តាមរដូវកាលអាចមានកាលវសាន ២១០ថ្ងៃ គិតពីថ្ងៃចេញផ្សាយ ។

ខ-មូលប័ត្ររដ្ឋដែលបានចេញផ្សាយជាសាធារណៈនិងមានកាលវសាន ៩០ថ្ងៃ គិត គិតពីថ្ងៃដែលបានធ្វើលទ្ធកម្ម ។

គ-មូលប័ត្រឥណទេយ្យឯកជនដែលអាចជួញដូរបានលើទីផ្សាររូបិយវត្ថុព្រមទាំងឥណទេយ្យឯកជនរបស់ធនាគារ ដែលមានហត្ថលេខាសាធនីយនិងដែលមានចុះនៅក្នុងបញ្ជីដោយទទួលស្គាល់ដោយក្រុមប្រឹក្សា ។

ឃ-មូលប័ត្ររបស់ធនាគារកណ្តាលផ្ទាល់ ។

២-ធនាគារកណ្តាលត្រូវកំណត់និងចេញផ្សាយនូវអត្រាអប្បបរមាសំរាប់ធ្វើបុនអប្បហារ បុរេប្រទាន ទទួលប៉ង់ស្យុង ឬឱ្យខ្ចី ។ ធនាគារកណ្តាលអាចកំណត់អត្រានិងពិជានអតិបរមាខុស១គ្នាសំរាប់ប្រតិបត្តិការ ឬកាលវសានផ្សេង១គ្នា ។

**មាត្រា ៣៧.-**

ធនាគារកណ្តាលអាចផ្តល់បុរេប្រទានលើគណនីចរន្តដល់ធនាគារពាណិជ្ជដែលធានាដោយមូលប័ត្ររដ្ឋឬមូលប័ត្រធានាដោយរដ្ឋ ។

**មាត្រា ៣៨.-**

១-គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវអនុវត្តតាមការណែនាំជាលាយល័ក្ខណ៍អក្សររបស់ធនាគារកណ្តាលដែលប្រកាសជារួមឬដោយឡែក ស្តីពីតារាងតុល្យការ ការសន្យាក្រៅតារាងតុល្យការនិងគណនីអាជីវកម្មដែលទាក់ទងទៅនឹង :

-ដើមទុនអប្បបរមា

-ចំនួនទឹកប្រាក់អប្បបរមានៃមូលនិធិសុទ្ធរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្ទាល់

-ការហាមឃាត់ ការដាក់កម្រិត ល័ក្ខខ័ណ្ឌ បញ្ញត្តិផ្សេង១

២-គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលធ្វើសកម្មភាពដូចគ្នានិងមានស្ថានភាពហិរញ្ញវត្ថុដូចគ្នាត្រូវស្ថិតនៅក្រោមបទបញ្ជាដូចគ្នា ។

**មាត្រា ៣៩.-**

១-គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវផ្តល់ជូនទៅធនាគារកណ្តាលនូវពត៏មានឬទិន្នន័យដែលធនាគារកណ្តាលសុំស្នើដើម្បីបំពេញមុខងាររបស់ខ្លួន ។

២-ក្នុងក្របខ័ណ្ឌរក្សាការសម្ងាត់វិជ្ជាជីវៈ ធនាគារកណ្តាលអាចបោះពុម្ពផ្សាយទាំងស្រុងឬមួយផ្នែកនូវពត៏មានទាំងនោះឬទិន្នន័យរួមតាមប្រភេទគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឬតាមប្រភេទសកម្មភាពរបស់គេ ។

៣-ធនាគារកណ្តាលទទួលរ៉ាប់រងលើគកំពស់សេវាអន្តរធនាគារដូចជាធ្វើមជ្ឈការនៃហានិភ័យ និងការមិនសងប្រាក់ណុលជាដើម ។

**មាត្រា ៤០.-**

ក្នុងកិច្ចសហប្រតិបត្តិការជាមួយធនាគារពាណិជ្ជ ធនាគារកណ្តាលត្រូវបង្កើតសភាផាត់ទាត់មួយសំរាប់បំរើការទូទាត់អន្តរធនាគារឱ្យឆាប់រហ័សនិងមានប្រសិទ្ធិភាព ។

## ជំពូកទី ៩
## រូបិយវត្ថុ

**មាត្រា ៤១.-**

ឯកតារូបិយវត្ថុរបស់កម្ពុជាគឺរៀល។ មួយរៀលស្មើនឹងដប់កាក់ មួយកាក់ស្មើនឹងដប់សេន។ សញ្ញាសំគាល់ប្រាក់រៀលគឺអក្សរ (៛) ។

**មាត្រា ៤២.-**

ធនាគារកណ្តាលមានសិទ្ធិផ្តាច់មុខក្នុងការបោះផ្សាយក្រដាសប្រាក់និងកាសជារៀល កាក់ និងសេន ។

**មាត្រា ៤៣.-**

១-ក្នុងពេលដែលមិនបានដកចេញពីចរាចរទេនោះ ក្រដាសប្រាក់និងកាសដែលបោះផ្សាយដោយធនាគារកណ្តាលគឺជារូបិយវត្ថុមានតម្លៃនីត្យានុកូលក្នុងព្រះរាជាណាចក្រកម្ពុជានិងមានតេជានុភាពធ្វើសេរីកាគ្មានព្រំដែនចំពោះក្រដាសប្រាក់ និងមានព្រំដែនចំពោះកាសក្នុងល័ក្ខខ័ណ្ឌកំណត់ដោយធនាគារកណ្តាល ។

២-ការទូទាត់ណាដែលមានចំនួនទឹកប្រាក់លើសពីការកំណត់របស់ធនាគារកណ្តាលអាចឬត្រូវតែធ្វើតាមលេខនា ។

**មាត្រា ៤៤.-**

១-ធនាគារកណ្តាលជាអ្នកទទួលបន្ទុកក្នុងការបោះពុម្ពក្រដាសប្រាក់ ចាក់ពុម្ពកាសនិងការងារពាក់ព័ន្ធឯទៀតដូចជាការធានាសន្តិសុខក្នុងការថែរក្សានិងចលនាក្រដាសប្រាក់និងកាសដែលមិនទាន់

បញ្ចេញផ្សាយ ការធានាថែរក្សានិងការបំផ្លាញចោលនៅពេលចាំបាច់នូវបណ្តាពុម្ពក្រដាស់ប្រាក់និងកាស ដែលដកចេញពីចរាចរ ។

២-ធនាគារកណ្តាលត្រូវកំណត់ដោយបទបញ្ជានូវលក្ខណៈផ្សេងៗ តម្លៃ ទំហំ ទម្ងន់ គំរូ និងលក្ខណៈរូបភាពផ្សេងៗទៀតរបស់ក្រដាសប្រាក់ដែលត្រូវបោះពុម្ពនិងកាសដែលត្រូវចាក់ពុម្ព ។

**មាត្រា ៤៥.-**

ធនាគារកណ្តាលមានសិទ្ធិសំរេចប្រកាសប្តូរ ក្រោយពីមានការយល់ព្រមពីរាជរដ្ឋាភិបាលដើម្បីដកចេញពីចរាចរនូវក្រដាសប្រាក់និងកាសដែលបានបោះផ្សាយរួចហើយ ។ ធនាគារកណ្តាលចំណាយសងតាមតម្លៃនៃក្រដាសប្រាក់ឬកាសទាំងនោះ ដោយប្តូរនឹងក្រដាសប្រាក់ឬកាសផ្សេងទៀតដែលខ្លួនបានបោះផ្សាយ ។ សេចក្តីសំរេចនេះត្រូវមានទម្រង់ជាបទបញ្ជារបស់ធនាគារកណ្តាលហើយត្រូវបញ្ជាក់ច្បាស់អំពីរយៈពេលនិងទីតាំងដែលត្រូវប្តូរក្រដាសប្រាក់និងកាសទាំងនោះ ។

**មាត្រា ៤៦.-**

នៅពេលចប់រយៈកាលប្តូរក្រដាសប្រាក់និងកាសដែលបានចែងក្នុងមាត្រា ៤៥ :

១-ក្រដាសប្រាក់និងកាសប្រមូលចូលដែលបានមកពីការប្តូរត្រូវតែលែងមានតម្លៃនីត្យានុកូល ។

២-ចំនួនទឹកប្រាក់ជាក្រដាសនិងជាកាសសរុបដែលបានប្រកាសឱ្យមកប្តូរតែមិនបានយកមកប្តូរ ត្រូវគិតដកចេញពីបរិមាណរូបិយវត្ថុនៅក្នុងចរាចរដែលចុះក្នុងបញ្ជីធនាគារកណ្តាលហើយត្រូវចាត់ទុកជាប្រាក់ចំណូលរបស់ធនាគារកណ្តាល ។

**មាត្រា ៤៧.-**

បើមានជនណាស្នើសុំប្តូរក្រដាសប្រាក់ឬកាសដែលធនាគារកណ្តាលបោះផ្សាយនោះ ធនាគារកណ្តាលត្រូវតែប្តូរឱ្យតាមតម្លៃស្មើដោយគ្មានគិតសោហ៊ុយអ្វីទាំងអស់ ។

**មាត្រា ៤៨.-**

ហាមមិនឱ្យផលិតជាថ្មីឡើងវិញនូវក្រដាសប្រាក់ កាស មូលប្បទានប័ត្រ មូលប័ត្រឬប័ណ្ណទូទាត់ផ្សេងៗទោះជារៀល ជាកាក់ ជាសេនក្តីឬជារូបិយវត្ថុបរទេសក្តីនិងមិនឱ្យបង្កើតវត្ថុទាំងឡាយណា

ដែលក្រាប់តាមក្រដាសប្រាក់ កាស មូលប្បទានប័ត្រ ប័ណ្ណទូទាត់ផ្សេងៗដោយពុំបានទទួលការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពីធនាគារកណ្តាលជាមុននោះទេ ។

**មាត្រា ៤៩.-**

ធនាគារកណ្តាលត្រូវតែគ្រប់គ្រងដោយផ្ទាល់នូវសន្និធិរូបិយវត្ថុបំរុងធ្វើផែនការបោះផ្សាយ និងធានាការផ្តល់ជាទៀងទាត់នូវក្រដាសប្រាក់និងកាស ដើម្បីបំពេញតម្រូវការរូបិយវត្ថុក្នុងព្រះរាជាណាចក្រកម្ពុជាទាំងបរិមាណនិងគុណភាព ។

**មាត្រា ៥០.-**

ធនាគារកណ្តាលត្រូវដកចេញពីចរាចរនូវរូបិយវត្ថុមិនគ្រប់លក្ខណៈប្រើប្រាស់ដើម្បីបំផ្លាញចោលហើយប្តូរថ្មីជំនួសវិញ ។

**មាត្រា ៥១.-**

ធនាគារកណ្តាលអាចបដិសេធមិនប្តូរក្រដាសប្រាក់និងកាស បើសិនជារូបភាពវាលែងមានភាពច្បាស់លាស់ បាត់បង់រូបភាពដើមឬឆ្នុះឆ្លាយឬដែលបាត់បង់ទំហំ ៣០% ( សាមសិបភាគរយ ) ឬលើសពីនេះ ។ រូបិយវត្ថុទាំងនេះត្រូវដកចេញពីចរាចរហើយបំផ្លាញចោលដោយគ្មានសំណងចំពោះម្ចាស់ទេ លើកលែងតែករណីពិសេសដែលធនាគារកណ្តាលអាចយល់ព្រមសងមួយចំណែកឬទាំងអស់ ។

**មាត្រា ៥២.-**

ក្រដាសប្រាក់ក្លែងក្លាយដែលយកមកបង់ឬប្តូរត្រូវរឹបអូសដោយគ្មានសំណង ហើយត្រូវជូនពត៏មានទៅអាជ្ញាធរមានសមត្ថកិច្ច ។

**មាត្រា ៥៣.-**

ម្ចាស់ប្រាក់មិនអាចទាមទារពីធនាគារកណ្តាលឱ្យសង ចំពោះក្រដាសប្រាក់ឬកាសណាដែលខ្លួនធ្វើឱ្យបាត់បង់ឬធ្វើឱ្យអន្តរាយឡើយ ។ ធនាគារកណ្តាលអាចដកហូតយកដោយគ្មានថ្លៃនូវក្រដាសប្រាក់ដែលមានការខូចខាតរូបភាពក្រៅ ជាពិសេសចំពោះក្រដាសប្រាក់ណាដែលមានសរសេរ លាបពណ៌ បោះពុម្ព បោះត្រាឬបិទវត្ថុស្អិតពីលើឬឆ្នុះឆ្លាយឬបាត់រូបភាពដោយប្រការណាក៏ដោយ ។

**មាត្រា ៥៤.-**

បរិមាណក្រដាសប្រាក់និងកាសកំពុងធ្វើចរាចរ ត្រូវកត់ត្រាចូលក្នុងគណនីទ្រព្យអកម្មរបស់ធនាគារកណ្តាលដោយមិនគិតបញ្ចូលនូវបរិមាណក្រដាសប្រាក់និងកាសនៅក្នុងសន្និធិរូបិយវត្ថុបំរុងទេ ។

## ជំពូកទី ១០
## គណនីនិងការពិនិត្យគណនី

**មាត្រា ៥៥.-**

ការិយបរិច្ឆេទគណនេយ្យនៃធនាគារកណ្តាល ចាប់ផ្តើមពីថ្ងៃទី០១ខែមករាដល់ថ្ងៃទី៣១ខែធ្នូ ជារៀងរាល់ឆ្នាំ ។

**មាត្រា ៥៦.-**

ធនាគារកណ្តាលត្រូវ :

១-កាន់កាប់បញ្ជីគណនេយ្យនិងបញ្ជីផ្សេងៗទៀតហើយត្រូវកត់ត្រាគ្រប់ប្រតិបត្តិការហិរញ្ញវត្ថុដែលឆ្លុះបញ្ចាំងដោយប្រាកដប្រជានូវស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួន ស្របទៅតាមគោលការណ៍និងបែបបទគណនេយ្យដែលត្រូវបានទទួលស្គាល់ជាទូទៅសំរាប់ធនាគារកណ្តាល ។

២-រៀបចំនិងចេញផ្សាយរបាយការណ៍សង្ខេបប្រចាំខែស្តីពីស្ថានភាពនៃសកម្មភាពរបស់ខ្លួន។

៣-ដាក់ជូនរាជរដ្ឋាភិបាលនិងរដ្ឋសភាក្នុងអំឡុង ៦ខែ បន្ទាប់ពីការបញ្ចប់ការិយបរិច្ឆេទនីមួយៗនូវច្បាប់ចម្លងនៃគណនីប្រចាំឆ្នាំ ព្រមទាំងរបាយការណ៍ដែលអាចចេញផ្សាយបាន ស្តីពីប្រតិបត្តិការរបស់ខ្លួននិងស្តីពីស្ថានភាពសេដ្ឋកិច្ចរូបិយវត្ថុក្នុងការិយបរិច្ឆេទកន្លងមក ។

**មាត្រា ៥៧.-**

ការពិនិត្យបញ្ជីហិរញ្ញវត្ថុរបស់ធនាគារកណ្តាល ត្រូវធ្វើឡើងដោយគណៈកម្មការពិសេសមួយដែលតែងតាំងដោយរាជរដ្ឋាភិបាល ។

# ជំពូកទី ១១

## បទបញ្ញត្តិផ្សេងៗ

**មាត្រា ៥៨.-**

ធនធាន ទ្រព្យសម្បត្តិ ប្រតិលាភ ប្រតិបត្តិការនិងអាជីវកម្មរបស់ធនាគារកណ្តាលត្រូវបាន លើកលែងមិនយកពន្ធនិងអាករឡើយ ។

**មាត្រា ៥៩.-**

ធនាគារកណ្តាលមិនត្រូវចូលហ៊ុនក្នុងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឬក្នុងសហគ្រាសដែល មានលក្ខណៈឧស្សាហកម្មឬពាណិជ្ជកម្មឡើយ លើកលែងតែគ្រឹះស្ថានដែលមានសកម្មភាពផ្សារភ្ជាប់ជាមួយ សកម្មភាពរបស់ធនាគារកណ្តាល ដូចជាការវាយតម្លៃនិងការពិនិត្យកិច្ចសន្យាធានា ប្រព្រឹត្តកម្មនិងការបញ្ជូន ទិន្នន័យ ការបោះពុម្ពឯកសារហិរញ្ញវត្ថុ ការផាត់ទាត់សងគ្នា ការបញ្ជូនសារលិខិតឬការជម្រះបញ្ជី ទ្រព្យសម្បត្តិក្នុងលក្ខខ័ណ្ឌដែលទឹកប្រាក់ចូលហ៊ុនទាំងអស់នោះមិនលើសពី ៥% ( ប្រាំភាគរយ ) នៃ មូលនិធិរបស់ខ្លួនផ្ទាល់ ។

**មាត្រា ៦០.-**

ធនាគារកណ្តាលមិនត្រូវធ្វើលទ្ធកម្មដោយទិញឬដោយភតិសន្យានូវសិទ្ធិពិតប្រាកដលើ អចលនទ្រព្យ លើកលែងតែទ្រព្យសម្បត្តិណាដែលចាំបាច់សំរាប់ធ្វើសកម្មភាពនិងមុខងាររបស់ខ្លួនឬសំរាប់ ការងារសង្គមកិច្ចចំពោះបុគ្គលិករបស់ខ្លួន ។

បទបញ្ញត្តិនៃមាត្រានេះពុំឃាត់ធនាគារកណ្តាលមិនឱ្យធ្វើលទ្ធកម្មក្នុងក្របខ័ណ្ឌនៃការទូទាត់ សងឥណទេយ្យរបស់ខ្លួននូវសិទ្ធិដែលមានចែងក្នុងមាត្រា ៥៥ឬមាត្រានេះទេ ។

**មាត្រា ៦១.-**

រាល់ប្រកាស បទបញ្ជា សារាចរនិងបណ្តាសេចក្តីណែនាំផ្សេងៗដែលចេញដោយធនាគារ កណ្តាលសំរាប់អនុវត្តជាទូទៅចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវធ្វើការផ្សព្វផ្សាយក្នុងរាជកិច្ចហើយ ចូលជាធរមានបញ្ញត្តិចាប់តាំងពីថ្ងៃចេញផ្សាយនោះឬតាមកាលកំណត់ដែលមានចែងក្នុង ប្រកាស បទបញ្ជា សារាចរនិងសេចក្តីណែនាំផ្សេងៗទាំងនោះ ។

**មាត្រា ៦២.-**

ដើម្បីអនុវត្តខ្លឹមសារនៃច្បាប់នេះ ធនាគារកណ្តាលអាចធ្វើបណ្តឹងខាងផ្នែករដ្ឋប្បវេណីភ្ជាប់ជាមួយផ្នែកព្រហ្មទណ្ឌនូវគ្រប់ដំណាក់កាលនៃនីតិវិធី ។

**មាត្រា ៦៣.-**

ការកម្រិតឥណទាននៅក្នុងចំណុច ៣ មាត្រា ២៥ នៃច្បាប់នេះ ត្រូវអនុវត្តចំពោះឥណទានណាដែលត្រូវផ្តល់ឱ្យក្រោយថ្ងៃដែលច្បាប់នេះចូលជាធរមាន ។

## ជំពូកទី ១២
## ទោសប្បញ្ញត្តិ

**មាត្រា ៦៤.-**

ជនណាពុំព្រមទទួលទាក់រូបិយវត្ថុដែលមានតម្លៃនីត្យានុកូលនិងមានតេជានុភាពធ្វើសេរីការលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជននោះនឹងត្រូវបានផ្តន្ទាទោសពិន័យជាប្រាក់ស្មើនឹង ១០០ដងនៃទឹកប្រាក់ដែលពុំព្រមទទួលទាក់នោះ ។

**មាត្រា ៦៥.-**

អ្នកក្លែងក្រដាសប្រាក់ឬកាសដែលជារូបិយវត្ថុមានតម្លៃនីត្យានុកូលនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាឬនៅលើដែនដីនៃរដ្ឋដទៃទៀតនឹងត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពី២០ឆ្នាំដល់អស់មួយជីវិត ។

វត្ថុតាងដែលរឹបអូសបានត្រូវទុកជាសម្បត្តិរដ្ឋឬបំផ្លាញចោល ។

**មាត្រា ៦៦.-**

ជនណាប្រព្រឹត្តដោយចេតនាដោយបញ្ចូលក្នុងចរាចរឬរក្សាទុកសំរាប់ចរាចរនូវក្រដាសប្រាក់ឬកាសក្លែងក្លាយ ជននោះនឹងត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំ ដល់ ២០ឆ្នាំ ។

**មាត្រា ៦៧.-**

ជនណាប្រើប្រាស់ឬរក្សាទុកដោយគ្មានការអនុញ្ញាតពីធនាគារកណ្ដាលនូវបណ្ដាសម្ភារៈ ឧបករណ៍ គ្រឿងយន្តនិងប្រដាប់សំរាប់ផលិតក្រដាសប្រាក់ឬកាស ជននោះនឹងត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ដល់ ១០ឆ្នាំ ។ ឯវត្ថុតាងនឹងត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋឬបំផ្លាញចោល ។

**មាត្រា ៦៨.-**

ជនណាទទួលក្រដាសប្រាក់ឬកាសដែលក្រោយមកបានដឹងថាជាក្រដាសប្រាក់ឬកាសក្លែងក្លាយហើយនៅតែយកទៅដាក់ឱ្យធ្វើចរាចរវិញ ជននោះត្រូវបានផ្ដន្ទាទោសពិន័យជាប្រាក់ស្មើនឹង ១០០ដង នៃទឹកប្រាក់នោះ ។

**មាត្រា ៦៩.-**

ដើម្បីអនុវត្តនិងបំពេញមុខងារឱ្យបានល្អតាមច្បាប់នេះ ធនាគារកណ្ដាលអាចស្នើសុំពត៌មានដែលខ្លួនត្រូវការពីរូបវន្តបុគ្គលឬនីតិបុគ្គលដែលពាក់ព័ន្ធ រួមទាំងពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនិងអង្គភាពក្រោមឱវាទទៀតផង ។

ជនណាដែលមិនព្រមផ្ដល់ពត៌មានដែលធនាគារកណ្ដាលបានស្នើសុំស្របតាមមាត្រានេះឬដែលមានចេតនាផ្ដល់ពត៌មានខុសឬបំភាន់ ជននោះនឹងត្រូវបានផ្ដន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ ៛ ( មួយលានរៀល ) ដល់ ១០.០០០.០០០ ៛ ( ដប់លានរៀល ) និង/ឬដាក់ពន្ធនាគារពី ១ឆ្នាំ ដល់ ៥ឆ្នាំ ។

**មាត្រា ៧០.-**

ជនណាគ្រប់គ្រងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឬធ្វើសកម្មភាពមានលក្ខណៈជាធនាគារដូចជាឥណទាន ជំនួញដើងសារូបិយប័ណ្ណ ការប្ដូររូបិយប័ណ្ណ ការទទួលប្រាក់ពីសាធារណជន ការគ្រប់គ្រងមធ្យោបាយទូទាត់ ប្រតិបត្តិការលើមូលប័ត្រ អាជីវកម្មមាស លោហធាតុនិងត្បូងថ្មមានតម្លៃដោយគ្មានការអនុញ្ញាតពីធនាគារកណ្ដាលត្រូវបញ្ឈប់សកម្មភាពភ្លាមតាមអធិបញ្ញារបស់ធនាគារកណ្ដាល ។ ជនដែលប្រព្រឹត្តល្មើសនឹងអធិបញ្ញានេះនឹងត្រូវបានផ្ដន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០៛ (មួយលានរៀល)ដល់ ១០.០០០.០០០ ៛ (ដប់លានរៀល) និង/ឬដាក់ពន្ធនាគារពី ១ឆ្នាំ ដល់ ៥ឆ្នាំ ។

មាត្រា ៧១.-

ជនណាប្រព្រឹត្តល្មើសនឹងមាត្រា ១៥ ចំណុច ១ និងមាត្រា ១៦ នឹងត្រូវបានផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ ៛ (មួយលានរៀល)ដល់ ១០.០០០.០០០ ៛ (ដប់លានរៀល) និង/ឬដាក់ពន្ធនាគារពី ១ឆ្នាំ ដល់ ៥ឆ្នាំ ។

## ជំពូកទី ១៣

## អវសានប្បញ្ញត្តិ

មាត្រា ៧២.-

បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ មករា ឆ្នាំ ១៩៩៦

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២**

**នរោត្តម រណឫទ្ធិ ហ៊ុន សែន**

បានបង្គំទូលថ្វាយនិងជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីទី១និងទី២

អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

**ហត្ថលេខា**

**ជា ចាន់តូ**

លេខ : ៣៦ ច.ល.

ថតចម្លងចេញពីច្បាប់ដើម

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

[illegible]រដ្ឋាភិបាល

[illegible]